ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អភិបាលកិច្ចល្អ

## អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

ខែ ធ្នូ ឆ្នាំ ២០០៨

# អភិបាលកិច្ចល្អ

ទំព័រ

សេចក្ដីផ្ដើម.....................................................................................................១

១- ទិដ្ឋភាពទូទៅ នៃអភិបាលកិច្ចល្អ

១.១ -និយមន័យ.......................................................................................៣

១.២ -គោលបំណងនៃអភិបាលកិច្ចល្អ.........................................................................៣

១.៣ -តួអង្គសំខាន់ នៃអភិបាលកិច្ច..................................................................៤

២- លក្ខណៈ នៃអភិបាលកិច្ចល្អ

ក-ប្រភេទ នៃអភិបាលកិច្ច

១-អភិបាលកិច្ចសេដ្ឋកិច្ច............................................................................៥

២-អភិបាលកិច្ចនយោបាយ..........................................................................៥

៣-អភិបាលកិច្ចរដ្ឋបាល............................................................................៥

៤-អភិបាលកិច្ចជាប្រព័ន្ធ............................................................................៥

ខ-គោលការណ៍ នៃអភិបាលកិច្ចល្អ

១-គិតពីសេវាសាធារណៈ...........................................................................៥

២-ការចូលរួមរបស់ប្រជាពលរដ្ឋ....................................................................៦

៣- នីតិរដ្ឋ..........................................................................................៦

៤-តម្លាភាព និងការឆ្លើយតប.......................................................................៧

៥-ការទទួលខុសត្រូវ និងគណនេយ្យភាព.........................................................៨

៦-ការចាត់ចែងល្អ និងប្រសិទ្ធភាពខ្ពស់.............................................................៨

៧-ការព្រមព្រៀងឯកភាពគ្នា និងសមធម៌..........................................................៩

៣- អភិបាលកិច្ចល្អ ក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់

៣.១-អភិបាលកិច្ច ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ នៃរាជរដ្ឋាភិបាល..................១០

៣.២- អភិបាលកិច្ច ក្នុងក្របខ័ណ្ឌច្បាប់ស្ដីពីការគ្រប់គ្រងឃុំ សង្កាត់.........................១១

៣.៣- អភិបាលកិច្ចក្នុងក្របខ័ណ្ឌច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.....................................................................................១២

354.968.GOV.COM
sh: Training



library.ncdd.gov.kh
015457

៣.៣.១-អំពីគោលការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ................១៣

៣.៣.២-អំពីគណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក............១៤

**៤-គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសំរាប់មន្ត្រីរដ្ឋាភិបាល**

៤.១-សេវាសាធារណៈ គឺជាទំនុកចិត្តរបស់សាធារណជន....................................១៥

៤.២-ការខិតខំអស់ពីសមត្ថភាព.................................................................១៥

៤.៣-រក្សាភាពឥតលំអៀង និងត្រឹមត្រូវ.......................................................១៥

៤.៤-គោរពប្រតិបត្តិរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋាននានា..........................១៦

៤.៥-ការគួរសមចំពោះសាធារណជន.............................................................១៦

៤.៦-ជៀសវាងអំពើពុករលួយ.....................................................................១៦

៤.៧-ជៀសវាងការខ្ជះខ្ជាយ ឬចាត់ចែងមិនត្រឹមត្រូវ........................................១៦

**៥-សន្និដ្ឋាន**.....................................................................................១៦

# អភិបាលកិច្ចល្អ

## សេចក្ដីផ្ដើម

អភិបាលកិច្ចជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជំរុញ និងគាំទ្រដំណើរការ នៃការគ្រប់គ្រងធនធាន ស្ថាប័ន អង្គភាព និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។

ជាសត្យានុម័ត គេបែងចែករបៀបគ្រប់គ្រងជាពីរប្រភេទគឺ អភិបាលកិច្ច និងបរិបាលកិច្ច ។ ដោយអនុលោមទៅតាមប្រភេទនៃអភិបាលកិច្ចនេះហើយ ទើបគេអាចឆ្លុះបញ្ចាំង និងវាយតម្លៃទៅលើសង្គមណាមួយក្នុងសកម្មភាពបែងចែកអំណាច និងការគ្រប់គ្រង ចាត់ចែងធនធាន ព្រមទាំងការដោះស្រាយបញ្ហាសង្គមនោះស្ថិតនៅក្នុងគន្លងអភិបាលកិច្ច ឬបរិបាលកិច្ច ។

អភិបាលកិច្ចប្រកបដោយសុភវិនិច្ឆ័យ ពោលគឺ អភិបាលកិច្ចល្អ ជាការចាត់ចែង និងគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបនឹងតំរូវការ និងផលប្រយោជន៍សង្គមជាតិទាំងមូល ។

ចំណែកឯនៅប្រទេសដែលពុំទាន់មានប្រជាធិបតេយ្យ ឬក៏មានប្រជាធិបតេយ្យមិនទាន់រឹងមាំ មិនសូវគោរពច្បាប់នោះ ការគ្រប់គ្រងសង្គមច្រើនតែផ្សារភ្ជាប់ទៅនឹងបរិបាលកិច្ច (Patronage) ។

ទំរង់ប្រជាធិបតេយ្យប្រកបដោយប្រសិទ្ធភាពនៃអភិបាលកិច្ច ជាប់ទាក់ទងនឹងការចូលរួមរបស់មហាជន ទំនួលខុសត្រូវ និង តម្លាភាព ។ វត្ថុបំណងជាចម្បងនៃទម្រង់ប្រជាធិតេយ្យដោយប្រសិទ្ធភាពគឺការលើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្ស ។

ភាពត្រឹមត្រូវតាមគោលនយោបាយ គឺជាល័ក្ខខ័ណ្ឌចាំបាច់ដំបូងគេបំផុត នៃអភិបាលកិច្ចល្អ ។ ភាពត្រឹមត្រូវតាមគោលនយោបាយ ត្រូវបានពិចារណា ដោយផ្ដោតសំខាន់ទៅលើកត្តាពីរយ៉ាងគឺៈ ទី១-ការគាំទ្រដោយប្រជាពលរដ្ឋច្រើនបំផុត ឬទាំងអស់ និងទី២-ការបំរើផលប្រយោជន៍ប្រជាពលរដ្ឋភាគច្រើន ឬទាំងអស់ ។ បើរដ្ឋ ស្ថាប័ន ឬអង្គភាព មិនមានភាពត្រឹមត្រូវតាមគោលនយោបាយទេ នោះយើងមិនអាចនិយាយអំពីអភិបាលកិច្ចល្អបានឡើយ ។

ទ្រឹស្ដីអភិបាលកិច្ចល្អ និងរដ្ឋាភិបាលល្អ ត្រូវបានលើកស្ទួយយ៉ាងខ្លាំង ចាប់ពីទស្សវត្សរ៍ ១៩៩០ ។ ប្រទេសកម្ពុជា បានទទួលឥទ្ធិពលនៃអភិបាលកិច្ចល្អពីប្រទេសអភិវឌ្ឍន៍នានា តាមរយៈអង្គការអន្តរជាតិ

ធនាគារពិភពលោក (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ហើយបានផ្សព្វផ្សាយអំពីអភិបាលកិច្ចល្អនេះ ចាប់តាំងពីឆ្នាំ ១៩៩៦ ។

យល់ឃើញអំពីសារៈសំខាន់នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថាអភិបាលកិច្ចល្អជា "**បុព្វល័ក្ខខ័ណ្ឌដ៏ចាំបាច់សំរាប់កិច្ចអភិវឌ្ឍន៍សង្គមកិច្ចប្រកបដោយនិរន្តរភាព និងសំរាប់យុត្តិធម៌សង្គម**" ។ ផែនការសកម្មភាពអភិបាលកិច្ចល្អ ត្រូវបានដាក់ឱ្យអនុវត្តនូវកំណែទម្រង់ដែលមានលក្ខណៈឆ្លងវិស័យសំរាប់ឆ្នាំ២០០១ និងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីគោលនយោបាយនៃ**យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា** ឆ្នាំ ២០០៤ ។

## ១. និដ្ឋភាពទូទៅ នៃអភិបាលកិច្ចល្អ

### ១.១ -និយមន័យនៃអភិបាលកិច្ចល្អ

• អភិបាលកិច្ច ត្រូវបានគេឱ្យនិយមន័យផ្សេងគ្នា អាស្រ័យស្ថានភាពជាក់ស្តែង ។ ជាសាមញ្ញ អភិបាលកិច្ច មានន័យថា:

ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។

ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 1997) បានឱ្យនិយមន័យថា អភិបាលកិច្ច ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការប្រទេស ។

### ១.២ –គោលបំណង នៃអភិបាលកិច្ចល្អ

គោលបំណងអភិបាលកិច្ច គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់នូវប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ ។

ដើម្បីសំរេចគោលបំណងខាងលើនេះ គេទទួលស្គាល់ជាទូទៅថា អភិបាលកិច្ច ទាមទារនូវការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព ។ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព ផ្តោតលើកិច្ចការសំខាន់ៗ ដូចខាងក្រោម:

-ត្រូវផ្តល់សេវាថែទាំសុខភាពល្អសមស្រប និងគ្រាប់គ្រាន់សំរាប់ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ ។ នេះជាកត្តាធ្វើឱ្យប្រជាពលរដ្ឋមានសុខមាលភាព និងថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ។

-ត្រូវមានសេវាអប់រំល្អសមស្រប និងគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យពួកគេមានចំណេះដឹង និងជំនាញពេញលេញក្នុងការបង្កើតឱកាសឱ្យបានច្រើន និងសមស្របបំផុតសំរាប់ខ្លួនគេ ។

-ត្រូវបង្កើតឱកាសសំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើ ដើម្បីរកបានប្រាក់ចំណូលគ្រប់គ្រាន់សំរាប់បំពេញតម្រូវការមូលដ្ឋាន ដូចជាស្បៀងអាហារ សំលៀកបំពាក់ ជំរក ជាដើម សំរាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ ។

ចំណុចសំខាន់ទាំងបីខាងលើនេះ ត្រូវបានអនុវត្តតាមមធ្យោបាយដែលធានាបាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព និងការថែរក្សាបរិស្ថាន ។

### ១.៣ -តួអង្គសំខាន់ នៃអភិបាលកិច្ច

កាលពីមុនគេយល់ឃើញថា មានតែរដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋាភិបាល) មួយគត់ដែលជាតួអង្គសំខាន់នៃអភិបាលកិច្ច ។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗជាច្រើនបានបង្ហាញឱ្យឃើញថា ផ្នែកឯកជន និងសង្គមស៊ីវិលផ្សេងៗទៀត ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ ។

ជាពិសេស ស្ថាប័នទាំងឡាយដែលមានភារកិច្ចជាអ្នកសំរេចចិត្តនោះ ត្រូវតែបើកទ្វារទូលំទូលាយឱ្យអង្គការសង្គមស៊ីវិល និងផ្នែកឯកជនចូលរួម ទើបការសំរេចចិត្តនោះឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ហើយគេនឹងពេញចិត្តអនុវត្តតាម ព្រោះគេយល់ថាអ្វីដែលបានពីការសំរេចចិត្តនោះ គឺជាសំលេងរបស់ពួកគេមួយផ្នែកដែរ ។

ដូចនេះ តួអង្គសំខាន់ក្នុងអភិបាលកិច្ច មានបីគឺៈ

-រដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋាភិបាលៈ ជាតួអង្គសំខាន់ជាងគេ)

-ផ្នែកឯកជន

-សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិល មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ អាស្រ័យលើល័ក្ខខ័ណ្ឌមួយចំនួនដូចជា ប្រព័ន្ធនយោបាយ លក្ខណៈអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកំរិតនៃការអភិវឌ្ឍសេដ្ឋកិច្ច ។ល។

ជាក់ស្តែងនៅប្រទេសខ្លះ ផ្នែកឯកជន និងសង្គមស៊ីវិល មានអំណាច និងវិសាលភាពយ៉ាងធំធេង ប៉ុន្តែប្រទេសមួយចំនួនផ្សេងទៀត ផ្នែកឯកជន និងសង្គមស៊ីវិល មានអំណាច ឱកាស និងឥទ្ធិពលតិចតួចទៅលើកិច្ចការប្រទេសជាតិ ។

## ២_លក្ខណៈ នៃអភិបាលកិច្ចល្អ

### ក-ប្រភេទសំខាន់ នៃអភិបាលកិច្ច

ប្រភេទទាំងបួន នៃអភិបាលកិច្ចត្រូវបានគេយកមកពិនិត្យថ្លឹងថ្លែង ដូចតទៅៈ

**១-អភិបាលកិច្ចសេដ្ឋកិច្ច** គឺជាដំណាក់ការនានានៃការសំរេចចិត្តដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើសកម្មភាពសេដ្ឋកិច្ចដទៃទៀត ។ អភិបាលកិច្ចសេដ្ឋកិច្ចនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើបញ្ហាសង្គមដូចជា ភាពត្រឹមត្រូវ ភាពក្រីក្រ និងគុណភាពនៃជីវភាព ។

**២-អភិបាលកិច្ចនយោបាយ** បានដល់ការសំរេចចិត្ត និងការអនុវត្តគោលនយោបាយរបស់នីតិប្រទេស (legitimate state) និងប្រទេសដែលប្រើអំណាចផ្តាច់ការ (authoritative state) ។ រដ្ឋត្រូវតែធ្វើឱ្យមានការបែងចែកឱ្យដាច់ស្រឡះរវាងអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវប្រកាន់យកគោលនយោបាយពហុភាព និងអនុញ្ញាតឱ្យពលរដ្ឋធ្វើការបោះឆ្នោតដោយសេរី ។

**៣-អភិបាលកិច្ចរដ្ឋបាល** គឺជាប្រព័ន្ធនៃការអនុវត្តន៍គោលការណ៍នយោបាយតាមរយៈ អង្គការសាធារណៈ ដែលមានប្រសិទ្ធភាព ឯករាជ្យ មានការទទួលខុសត្រូវ និងមានភាពចំហ ។

**៤-អភិបាលកិច្ចជាប្រព័ន្ធ** គឺជាអភិបាលកិច្ចដែលក្រសោបដំណើរការ និងរចនាសម្ព័ន្ធសង្គមដែលធ្វើឱ្យមានទំនាក់ទំនងផ្នែកនយោបាយសង្គម សេដ្ឋកិច្ច ដើម្បីការពារវប្បធម៌ ជំនឿសាសនា និងតំលៃសីលធម៌ និងដើម្បីបង្កើត និងថែរក្សាបរិស្ថានសុខភាព សេរីភាព សន្តិសុខ និងដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបប្រើប្រាស់សមត្ថភាពរបស់ពួកគេ ក្នុងការកសាងជីវភាពឱ្យបានខ្ពង់ខ្ពស់ ។

ប្រព័ន្ធអភិបាលកិច្ចរៀបចំនេះ គេច្រើនតែជួបប្រទះនៅក្នុងប្រទេសរីកចំរើន ដែលនៅក្នុងប្រទេស នោះធនធានមនុស្សមានការអភិវឌ្ឍន៍ខ្ពស់ និងមានការគោរពអនុវត្តច្បាប់បានត្រឹមត្រូវ និងមានគុណភាព ខ្ពស់ ។

## ខ-គោលការណ៍ នៃអភិបាលកិច្ច

### ១-គិតពីសេវាសាធារណៈ

នេះជាទស្សនៈដែលចែងថារដ្ឋាភិបាលកើតឡើងដើម្បីបម្រើប្រជាពលរដ្ឋ ពុំមែនសំរាប់ប្រើអំណាចត្រួតត្រាពលរដ្ឋទេ ។ ការបម្រើ (ឬការផ្តល់សេវា) គឺមិនមែនជាការប្រើអំណាចត្រួតត្រាទេ ។ គោលនយោបាយ ឬសកម្មភាពណាមួយ ដែលធ្វើដោយរដ្ឋាភិបាល អាច ឬត្រូវបានវិនិច្ឆ័យថាល្អ ឬអាក្រក់ដោយឆ្លើយទៅនឹងសំណួរថា " តើការនេះផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋដែរឬទេ? ។

សំណួរនេះអាចនាំទៅរកការផ្លាស់ប្តូរនៅក្នុងសកម្មភាពរបស់រដ្ឋាភិបាល ។ មានកិច្ចការខ្លះត្រូវបានធ្វើឡើងដោយពុំមានគោលបំណងល្អសោះ ។ កិច្ចការខ្លះទៀតពុំអាចមានអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋឡើយ ឬអាចមានគ្រោះថ្នាក់ថែមទៀត ។

### ២-ការចូលរួមរបស់ប្រជាពលរដ្ឋ

#### ២.១-ការចូលរួមដោយផ្ទាល់:

ក្នុងរបបប្រជាធិបតេយ្យប្រជាពលរដ្ឋមានសិទ្ធិចូលរួមដោយផ្ទាល់ពាក់ព័ន្ធនឹងកិច្ចការសាធារណៈនិងកិច្ចអភិវឌ្ឍន៍មូលដ្ឋានៈ

-បោះឆ្នោត

-ចូលរួមក្នុងគណបក្សនយោបាយ

-ឈរឈ្មោះបោះឆ្នោត

-បង្កើតសមាគម

-ធ្វើការសំរេចចិត្ត និងអនុវត្តសេចក្ដីសំរេចចិត្តនៃសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ។ល។

#### ២.២-ការចូលរួមតាមរយៈអ្នកតំណាងៈ

អ្នកតំណាង ត្រូវបំពេញតួនាទីជាអ្នកតំណាងឱ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ ។អ្នកតំណាងប្រជាពលរដ្ឋ អាចត្រូវបានជ្រើសរើសតាមនីតិវិធីផ្សេងៗ ទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្ដែង ដូចជាៈ

-ការបោះឆ្នោតសកល ឬអសកល (សមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)

-ការតែងតាំង និងជ្រើសរើស ជាដើម ។

ឧទាហរណ៍ ក្រុមប្រឹក្សាខេត្ត ជាអ្នកតំណាងប្រជាពលរដ្ឋទាំងមូលនៅក្នុងខេត្តរបស់ខ្លួន ដូច្នេះក្រុមប្រឹក្សាខេត្ត ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសំរេច ធានាបានការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

### ៣- នីតិរដ្ឋ

នីតិរដ្ឋក្នុងន័យអភិបាលកិច្ច ទាមទារឱ្យមានឯកសារក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបំរើ និងការពារផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលំអៀង ។ លើសពីនេះ ច្បាប់ទាំនេះ ត្រូវតែការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ។ ដូច្នេះត្រូវមានប្រព័ន្ធតុលាការឯករាជ្យនិងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀងនិងមិនពុករលួយ ។

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អផ្តោតជាសំខាន់ទៅលើៈ

**៣.១-មានឯកសារក្របខ័ណ្ឌច្បាប់ គោរពច្បាប់ និងអនុវត្តច្បាប់**

-គោលការណ៍ៈ តាមការវិវត្តន៍របស់សង្គម និងតាមតំរូវការនៃការគ្រប់គ្រងរដ្ឋ

-ច្បាប់ផ្ទៃក្នុងៈ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស បទបញ្ជា...

-ច្បាប់អន្តរជាតិៈ សន្ធិសញ្ញា អនុសញ្ញា កតិកាសសញ្ញា ពិធីសារ...

**៣.២-មានប្រព័ន្ធទទួលខុសត្រូវ**

-ខាងអំណាចនយោបាយៈ សភា រដ្ឋាភិបាល ប្រមុខរដ្ឋ

-ខាងអំណាចនីតិបញ្ញត្តិៈ សភាទទួលខុសត្រូវធ្វើច្បាប់

-ខាងអំណាចប្រតិបត្តិៈ រដ្ឋបាល អាជ្ញាធរដែនដី មន្ត្រីរាជការ

-ខាងអំណាចតុលាការៈ ជាអ្នកធ្វើឱ្យគោរពច្បាប់ ចៅក្រម

**៣.៣-មានប្រព័ន្ធយុត្តិធម៌**

-គោលការណ៍ៈ ឯករាជ្យ និង យុត្តិធម៌

-ប្រព័ន្ធក្នុងតុលាការៈ

-តុលាការខេត្ត ក្រុង និងតុលាការយោធា

-សាលាឧទ្ធរណ៍

-តុលការកំពូល

-ប្រព័ន្ធក្រៅតុលាការៈ

-ការចរចារ

-សន្ធានកម្ម ឬការផ្សះផ្សារ

-មជ្ឈត្តវិនិច្ឆ័យ

**៤-តម្លាភាព និង ការឆ្លើយតប**

តម្លាភាពមានន័យថា ភាពបើកចំហ សាធារណជនត្រូវតែអាចឃើញ ដឹង ឮ នូវអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ ជាទូទៅការងាររដ្ឋាភិបាល គឺជាការងាររបស់ប្រជាពលរដ្ឋ ហើយមិនត្រូវមានការលាក់បាំងទេ ។ រដ្ឋាភិបាលត្រូវតែបើយចំហជូនប្រជាពលរដ្ឋធ្វើអធិការកិច្ច ហើយផ្សព្វផ្សាយពតិមានអំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ ការនេះអាចឱ្យប្រជាពលរដ្ឋមើលឃើញថា អ្វីៗដែលរដ្ឋាភិបាលកំពុងធ្វើ

និងរៀបចំធ្វើ គឺធ្វើក្នុងនាមប្រជាពលរដ្ឋ ហើយឆ្លើយតបទៅនឹងផលប្រយោជន៏របស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាលអនុវត្តនយោបាយតម្លាភាពដោយផ្តល់ពត៌មានទៅឱ្យសាពត៌មាន ដោយការឆ្លើយតបដោយចេតនាទៅនឹងសំណួរ ឬសំណើសុំព័ត៌មានពីសំណាក់អ្នកការសែត ពីសំណាក់សមាជិករដ្ឋសភា និងពីសំណាក់សាធារណជន ហើយនិងដោយមានការបោះពុម្ពផ្សាយឯកសារជាច្រើន ដែលពន្យល់អំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។

### ៥-ការទទួលខុសត្រូវ និង គណនេយ្យភាព

ការទទួលខុត្រូវមានន័យថា រដ្ឋាភិបាលទទួលខុសត្រូវចំពោះសាធារណជនពីអ្វីដែលខ្លួនធ្វើ ។ គណនេយ្យភាព មានន័យថា រដ្ឋាភិបាលត្រូវតែពន្យល់ និងបញ្ជាក់ពីសកម្មភាព និង សេចក្តីសំរេចរបស់ខ្លួនជូនសាធារណៈ ហើយថាតើរដ្ឋាភិបាលចំណាយប្រាក់ជាថវិកាជាតិយ៉ាងណាខ្លះ ។

មន្ត្រីសាធារណៈទាំងអស់ ក៏មានការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះអ្វីដែលខ្លួនធ្វើដែរ ។ ការនេះមន្ត្រីសាធារណៈ ត្រូវមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះមុខ សាធារណជន ។ មន្ត្រីសាធារណៈទាំងអស់ ត្រូវមានគណនេយ្យភាពចំពោះមុខសាធារណជន ពីព្រោះ ពួកគេបានតែងតាំងឡើងដើម្បីបំរើសាធារណជន ។ កាលពីមុន គេសង្កេតឃើញថា មន្ត្រីរាជការ ត្រូវបាន តែងតាំងឡើងដើម្បីដឹកនាំប្រជាពលរដ្ឋ ។ ប៉ុន្តែបច្ចុប្បន្ននេះ តួនាទីរបស់មន្ត្រីរាជការ គឺផ្តោតទៅលើការផ្តល់សេវាជូនប្រជាពលរដ្ឋ ។

មិនមែនមានតែរដ្ឋាភិបាល ស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេដែលត្រូវមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ក៏ត្រូវមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ អំពីការសំរេចចិត្ត ។

### ៦-ការចាត់ចែងល្អ និង ប្រសិទ្ធភាពខ្ពស់

ការចាត់ចែងល្អ គឺជាប្រធានបទទាំងមូលសំរាប់ធ្វើការសិក្សាដ៏យូរអង្វែង ។ ប៉ុន្តែនិយាយដោយសង្ខេប ការចាត់ចែងល្អមានលក្ខណៈដូចគ្នា ទោះរដ្ឋាភិបាលក្តី អង្គការឯកជនក្តី ។ នេះមានន័យថារដ្ឋាភិបាលមានប្រព័ន្ធមួយសំរាប់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិ គឺថាបានទទួលលទ្ធផលទាន់ពេល និងមិនខ្ជះខ្ជាយធនធាន ។

ការចាត់ចែងល្អ ផ្សារភ្ជាប់ទៅនឹងប្រសិទ្ធភាពខ្ពស់ផងដែរ ។ ប្រសិទ្ធភាពខ្ពស់ក្នុងន័យអភិបាលកិច្ច មានន័យថា ជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព

និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធភាពមានគុណភាពខ្ពស់ បរិមាណច្រើន អាចបំរើផលប្រយោជន៍ ជាអតិបរិមា និងបានឆ្លើយតបទៅនឹងតំរូវការពិតរបស់សង្គម ។ គោលគំនិតនៃប្រសិទ្ធភាពខ្ពស់ នៅក្នុងបរិបទអភិបាលកិច្ចល្អ ក៏រាប់បញ្ចូលផងដែរចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការពារបរិស្ថាន ។ ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត ត្រូវពិចារណាលើចំណុចមួយចំនួន ដូចខាងក្រោម :

-ការប្រើប្រាស់ធនធាន( ធនធានមនុស្ស ថវិកា ហិរញ្ញវត្ថុ សម្ភារៈ ពេលវេលា) ឱ្យបានត្រឹមត្រូវ

-ការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់

-ជៀសវាងការអនុវត្តនូវកាកិរិយាធិបតេយ្យ

-ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ

-គ្មានអំពើពុករលួយ

-ការសំរេចចិត្តតាមបែបវិមជ្ឈការ ។

**៧-ការព្រមព្រៀងឯកភាពគ្នា និង សមធមិ**

ការព្រមព្រៀងឯកភាពគ្នា ក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋ ឬអ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសំរេចចិត្តដោយមានការឯកភាពគ្នាលើជម្រើស និង វិធីសាស្ត្រណាមួយដែលបំរើផលប្រយោជន៍សាធារណៈ ។

សមធមិ ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់ក្នុងការចូលរួម បញ្ចេញយោបល់លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលំអ និងថែរក្សាសុខមាលភាពរបស់ពួកគេ ។ សុខមាលភាព ផ្តោតជាសំខាន់ទៅលើភាពសប្បាយរីករាយ ភាពសុខស្រួល សុវត្ថិភាព សន្តិសុខ សុខភាព គុណភាពនៃជីវភាព ។ សុខមាលភាពរបស់បុគ្គល មិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុណ្ណោះទេ តែត្រូវគិតដល់ផ្នែកជំនឿ សាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ ព្រមទាំងភាពគ្រប់គ្រាន់នៃជីវភាពរស់នៅផងដែរ ។

## ៣-អភិបាលកិច្ចល្អ ក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់

### ៣.១-អភិបាលកិច្ច ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ នៃរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា បន្តអនុវត្តគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណ សំដៅលើកស្ទួយកិច្ចអភិវឌ្ឍន៍លើគ្រប់វិស័យរបស់ប្រទេសកម្ពុជា ។

គោលការណ៍កំណែទម្រង់សំខាន់ៗ ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផ្តោតលើ **អភិបាលកិច្ចល្អ** ជាស្នូល សំដៅលើកំណែទម្រង់វិស័យបួនសំខាន់គឺ:

-កំណែទម្រង់រដ្ឋបាលសាធារណៈ

-កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ

-ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

-កំណែទម្រង់កងកំលាំងប្រដាប់អាវុធ

កំណែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើការធានាផ្តល់សេវាសាធាណៈជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្នុងវិស័យអាទិភាព ៤ នៃសេវាសាធារណៈគឺ:

ទី១: សេវាពាក់ព័ន្ធនឹងអាធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ (ឧទាហរណ៍ អត្រានុកូលដ្ឋាន លិខិតអនុញ្ញាតផ្សេងៗ ប័ណ្ណកម្មសិទ្ធិដីធ្លី)

ទី២: សេវាពាក់ព័ន្ធនឹងការវិនិយោគ

ទី៣: សេវាមូលដ្ឋាន (អប់រំ និងសុខាភិបាល)

ទី៤: សេវាពាក់ព័ន្ធនឹងចំណូលចំណាយរបស់រដ្ឋ

នីតិវិធី នៃការទទួលសេវាសាធារណៈ ត្រូវធ្វើឱ្យសាមញ្ញ តាមរយៈយន្តការ" ច្រកចេញចូលតែមួយ" ការកាត់បន្ថយការិយាល័យធិតេយ្យ ព្រមទាំងបង្កើតការិយាល័យប្រជាពលរដ្ឋ ។ ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ តាមរយៈការរៀបចំរដ្ឋបាលដែនដី នៃព្រះរាជាណាចក្រកម្ពុជា តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍រដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់លការអភិវឌ្ឍន៏តាមបែបប្រជាធិបតេយ្យ ។ រដ្ឋបាលឯកភាពនេះ ជួយគាំទ្រឃុំ សង្កាត់ ដើម្បីអភិវឌ្ឍន៍មូលដ្ឋានដោយខ្លួនឯង និងរួមចំណែកពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ។

កំណែទម្រង់ច្បាប់ និងតុលាការ រាជរដ្ឋាភិបាលជំរុញធានានូវឯករាជភាព អាព្យាក្រឹតភាព នៃប្រព័ន្ធតុលាការ ។ ក្នុងគោលដៅនេះ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានដំណើរការប្រព្រឹត្តិទៅដោយ

ឯករាជភាពពិតប្រាកដ ។ ដើម្បីកំណែទម្រង់ច្បាប់ និងតុលាការ រាជរដ្ឋាភិបាល រៀបចំគំរោងជាអាទិភាពនូវបណ្តាច្បាប់ជាមូលដ្ឋាន ដើម្បីដាក់ឆ្លងរដ្ឋសភា មានជាអាទិ៍ ច្បាប់លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្រមព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសារការី និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាសាលា ។ ច្បាប់ និងលិខិតបទដ្ឋានមួយចំនួនទៀត នឹងត្រូវបង្កើត ដើម្បីបំពេញបន្ថែមទៅលើក្របខ័ណ្ឌគតិយុត្តិបច្ចុប្បន្ន ។ ជាពិសេស រាជរដ្ឋាភិបាល នឹងរៀបចំឱ្យមានតុលាការឯកទេសមួយចំនួនតាមតំរូវការចាំបាច់ មានជាអាទិ៍ តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល ។

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដោយជំរុញការអនុម័តច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ និង ការបង្កើតស្ថាប័នឯករាជអាព្យាក្រឹត្យមួយ សំរាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ ព្រមទាំងជំរុញប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសតាមរយៈការពង្រឹងការងារសវនកម្ម និងលទ្ធកម្មសាធារណៈ ក៏ដូចជាជម្រុញអនុវត្តកំណែទម្រង់ដែលមានការពាក់ព័ន្ធគ្រប់វិស័យ ដើម្បីធានានូវអភិបាលកិច្ចល្អ ។ ពិសេស ការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ក្រសួង-ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងដៃគូរផ្តល់ជំនួយ ។

កំណែទម្រង់កងកំលាំងប្រដាប់អាវុធ ដោយបន្តអនុវត្តគោលនយោបាយដែលបានលើកឡើងក្នុងសៀវភៅ ៩ របស់កងយោធពលខេមរភូមិន្ទ ។ កំណែទម្រង់កងយោធពលខេមរភូមិន្ទ បង្កើតនូវប្រព័ន្ធគ្រប់គ្រងកងយោធពលខេមរភូមិន្ទ ប្រព័ន្ធបណ្តុះបណ្តាល និង កិច្ចសហប្រតិបត្តិការ នៃវិស័យកងទ័ព ។ រាជរដ្ឋាភិបាល នឹងជំរុញអនុវត្តគោលនយោបាយកំណែទម្រង់នគរបាលជាតិ ដោយផ្តោតជាអាទិភាពពិសេសទៅលើការរៀបចំឱ្យប្រើប្រាស់ប្រព័ន្ធបៀវត្សរបស់នគរបាល និងកងទ័ពអោយមានភាពរលូន ជាមួយប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិល ។

**៣.២-អភិបាលកិច្ច ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់**

ច្បាប់**ស្តីពីការគ្រប់គ្រងឃុំ សង្កាត់** មានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា តាមនយោបាយវិមជ្ឈការ ។ ឃុំ សង្កាត់ ជានីតិបុគ្គល ។

រដ្ឋបាលឃុំ សង្កាត់ មានតួនាទីជំរុញ និងគាំពារ**អភិបាលកិច្ចល្អ** ដោយចាត់ចែងប្រើប្រាស់ធនធានដែលមានប្រកបដោយចិរភាព សំរាប់សេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផល ប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិ ស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌ នៃឃុំ សង្កាត់នីមួយៗ ។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ តួនាទីបំរើការការងារមូលដ្ឋានសំរាប់ ផលប្រយោជន៍ ឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់របស់ខ្លួន និង តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ ឧទាហរណ៍ តួនាទីអភិវឌ្ឍន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការអភិវឌ្ឍន៍ ដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ ដូចជាប្រជាពលរដ្ឋ និងសង្គមស៊ីវិល ដើម្បីធានានូវអភិបាលកិច្ច នៃការគ្រប់គ្រង ចាត់ចែងកិច្ចការមូលដ្ឋាន ក្របដោយប្រសិទ្ធភាព ខ្ពស់ តម្លាភាព និងការចូលរួម ។

ឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសសកម្មបំរើ ផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ទាក់ទិននឹងសកម្មបំរើ ផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សា ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលចំពោះការប្រតិបត្តិច្បាប់ រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន។

### ៣.៣-អភិបាលកិច្ច ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

#### ៣.៣.១-អំពីគោលការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បី បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាបញ្ហាសំខាន់នៃអភិបាលកិច្ចល្អ ។ ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ គឺជាការអភិវឌ្ឍដែលមានដំណើរការដោយមានលក្ខណៈដូចខាងក្រោមៈ

**-ភាពជាតំណាងសាធារណៈ** (Public Representation) ៈក្រុមប្រឹក្សាត្រូវអនុវត្តការងារ ក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**-ស្វ័យភាពរបស់មូលដ្ឋាន** (Local Autonomy) ៈស្ថានភាពដែលក្រុមប្រឹក្សាអាចជាម្ចាស់ ការចាត់ចែង គ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬធ្វើប្រតិភូកម្មឱ្យដោយច្បាប់នេះប្រកបដោយប្រសិទ្ធភាព។

**-ការពិគ្រោះយោបល់ និងការចូលរួម** (Consultation Participation) :ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលក្រុមប្រឹក្សាត្រូវ:

-ជួប និង ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន

-លើកទឹកចិត្តនិងសំរបសម្រួល អោយមានការចូលរួម របស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ចដើម្បីស្វែងយល់ និង ឆ្លើយតបតំរូវការរបស់ប្រជាពលរដ្ឋ ។

**-ឆ្លើយតបនិង គណនេយ្យភាព** (Responsiveness and Accountability) : ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសំរេចចិត្ត សកម្មភាព និង ការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ នូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរដ្ឋាភិបាល ក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

**-លើកកំពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន** (Promotion of Life Quality of the Local Residents) សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បី:

-បង្កើត និងធ្វើអោយមាននិរន្តរភាព នូវបរិកាសមួយប្រកមដោយសន្តិភាព សុវត្ថិភាព និង សុខមាលភាព

-លើកកំពស់ការអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ច និង

-លើកកំពស់ផាសុខភាព និង គុណភាពជីវិត នៃ ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

**-លើកស្ទួយសមធម៌** (Promotion of Eguity): ការគិតគូរ និងយកចិត្តទុកដាក់ ជាពិសេសទៅលើតំរូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និង កុមារ ព្រមទាំងតំរូវការខុសៗគ្នារបស់ ក្រុមជនងាយរងគ្រោះរាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និង ជនជាតិដើមភាគតិច ។

**-តម្លាភាព និង សុច្ចរិតភាព** (Transparency and Integrity) :គឺជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានារាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុច្ចរិតភាព និង ច្បាប់ក្នុងលក្ខណៈបើកចំហ តម្លាភាព ភាពចូលរួម ភាពឆ្លើយតប ។

**-វិធានការប្រឆាំងអំពើពុករលួយនិង ការរំលោភអំណាច** (Measures to Fight Corruption and Abuse of Power) :គឺជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និង ការរំលោភអំណាច ។

រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**៣.៣.២-អំពីគណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក**

**ក-គណនេយ្យភាពចំពោះប្រជាពលរដ្ឋ**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយ ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើការអង្កេតនោះ រួចហើយ ត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល ។

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុឱ្យមានតម្លាភាព និង មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**ខ-គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាល ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ។

**គ-ការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះថ្នាក់លើ**

បុគ្គលិកទាំងអស់ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធាន គ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះ នាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម ។

## ៤-គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសំរាប់មន្ត្រីរដ្ឋាភិបាល

រដ្ឋាភិបាលសម័យទំនើបមានក្រមប្រតិបត្តិ ឬក្រមចរិយាធម៌សំរាប់មន្ត្រីរបស់ខ្លួន ។ ក្រមទាំងនោះកំណត់ពីចរិយាត្រូវ និងខុស ហើយតម្រូវឱ្យមន្ត្រីទាំងនេះប្រកាន់យកតែចរិយាល្អ ។ ថ្នាក់លើ ត្រូវត្រួតពិនិត្យមើលមន្ត្រីរបស់ខ្លួន ដើម្បីឱ្យដឹងច្បាស់ថាគេទាំងនោះគោរពតាមបទដ្ឋានទាំងនោះដែរឬទេ ។ ការរំលោភទៅលើក្រមចរិយាធម៌ត្រូវទទួលទោសផ្នែកវិន័យ ដោយរួមទាំងការបណ្តេញចោល ឬនៅក្នុងករណីធ្ងន់ធ្ងរជាច្រើនទៀតត្រូវប្តឹងចោទប្រកាន់ជាបទឧក្រិដ្ឋ ។

គោលការណ៍ទាំងនេះ គឺជាការណែនាំផ្ទាល់សំរាប់មន្ត្រីទាំងអស់ ។ គោលការណ៍ទាំងនេះមានគោលបំណងរក្សាបទដ្ឋាននៃចរិយាល្អទូទៅ ផ្តល់សេវាល្អដល់សាធារណជន ហើយជៀសវាងការបាត់បង់នានាដែលបណ្តាលមកពីអំពើពុករលួយ ឬការគ្មានប្រសិទ្ធភាព ។

គោលការណ៍ជាមូលដ្ឋានសំរាប់មន្ត្រីរដ្ឋាភិបាលប្រកាន់យកមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងប្រទេសទាំងអស់ ។ គោលការណ៍នេះ ជំរុញការអនុវត្តអភិបាលកិច្ចល្អក្នុងការប្រតិបត្តិការងារ ។

### ៤.១-សេវាសាធារណៈ គឺជាទំនុកចិត្តរបស់សាធារណជន

នេះជាគោលការណ៍មូលដ្ឋានដ៏សំខាន់បំផុត ដែលគូសបញ្ជាក់ពីចរិយាជាផ្លូវការ ។ មានន័យថាអ្នកកំពុងធ្វើការក្នុងនាមប្រជាពលរដ្ឋ ។ ដើម្បីវិនិច្ឆ័យថាអ្នកកំពុងធ្វើអ្វីមួយត្រឹមត្រូវឬទេ អ្នកអាចសួរខ្លួនអ្នកថា តើខ្ញុំកំពុងតែបំរើសាធារណជនដោយស្មោះត្រង់ឬទេ? នេះជាខ្នាតគំរូដែលអ្នកត្រូវប្រតិបត្តិ ។

### ៤.២-ការខិតខំអស់ពីសមត្ថភាព

មន្ត្រីគ្រប់រូបត្រូវបានគេសង្ឃឹមថានឹងធ្វើការយ៉ាងខ្លាំងក្លា និង ផ្តល់ការខិតខំយ៉ាងត្រឹមត្រូវចំពោះការងារ ។

### ៤.៣-រក្សាភាពឥតលំអៀង និងត្រឹមត្រូវ

មន្ត្រីរដ្ឋាភិបាលត្រូវផ្តល់សេវានានា ដោយពុំមានការផ្តល់ភាពអនុគ្រោះពិសេសចំពោះ មិត្តភក្តិញាតិសន្តាន សមាជិករបស់គណបក្សនយោបាយណាមួយ ផលប្រយោជន៍ពាណិជ្ជកម្មពិសេស ឬអ្វីផ្សេងទៀតឡើយ ។ រដ្ឋាភិបាលជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋទាំងអស់គ្នា ដែលត្រូវតែបំរើដល់ជនគ្រប់រូបដោយឥតប្រកាន់បក្សពួក ។

### ៤.៤-គោរពប្រតិបត្តិរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាន

មន្ត្រីគ្រប់រូបត្រូវតែប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋាន នៅគ្រប់កាលៈទេសៈ ។ មន្ត្រីមិនត្រូវសំរេចបញ្ហានានាដោយបំពាន ឬដោយទំនើងចិត្ត ផ្ទាល់ខ្លួនឡើយ ។

**៤.៥-ការគួរសមចំពោះសាធារណជន**

ប្រជាពលរដ្ឋដែលរដ្ឋាភិបាលអញ្ជើញឱ្យចូលមកធ្វើការប្រាស្រ័យទាក់ទង ត្រូវតែបានទទួលការស្វាគមន៍ ដោយការគួរសម និង ភាពថ្លៃថ្នូរ ។

**៤.៦-ការមិនប្រព្រឹត្តអំពើពុករលួយ**

មន្ត្រីរដ្ឋាភិបាលមិនត្រូវប្រើប្រាស់ការិយាល័យរបស់ខ្លួនដើម្បីទទួលសំណូក មិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដើម្បីផលប្រយោជន៍ផ្ទាល់របស់ខ្លួន ឬចូលរួមក្នុងការប្រព្រឹត្តិអំពើពុករលួយបែបណាមួយឡើយ ។

**៤.៧-ជៀសវាងការខ្ជះខ្ជាយ ឬចាត់ចែងមិនត្រឹមត្រូវ**

មន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិ ឬបរិក្ខាដែលខ្លួនប្រើប្រាស់ហើយមិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬបរិក្ខាដោយខុសទិសដៅ ឬដោយខ្ជះខ្ជាយឡើយ ។

**៥-សន្និដ្ឋាន**

ទាំងការគ្រប់គ្រងធនធានមនុស្ស ទាំងស្ថាប័ន អង្គភាព និងការផ្តល់សេវាសាធារណៈ ទាមទារឱ្យមានអភិបាលកិច្ចល្អ ជាកត្តាចាំបាច់សំរាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ ផ្ទុយទៅវិញ កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន និងការផ្តល់សេវាសាធារណៈ មិនអាចដំណើរការទៅបានល្អ ប្រសិនបើការគ្រប់គ្រងមានលក្ខណៈបរិបាលកិច្ច ។ ឈរលើសារៈសំខាន់នៃ អភិបាលកិច្ចល្អ រាជរដ្ឋាភិបាល បានកំពុង និងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ ដោយបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងបានបញ្ចូលគោលការណ៍ នៃអភិបាលកិច្ចល្អ ទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល និងច្បាប់រៀបចំអង្គការ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រទេសប្រកបដោយជោគជ័យ ។

# អភិបាលកិច្ចល្អ

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

ខែ ធ្នូ ឆ្នាំ ២០០៨

1

## គោលបំណង និងមាតិកា

**គោលបំណង** ដើម្បីស្វែងយល់អំពីបរិបទអភិបាលកិច្ច ក្នុងការជំរុញ គាំទ្រដំណើរការគ្រប់គ្រងធនធានស្ថាប័ន អង្គភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

**មាតិកា**

១-ទិដ្ឋភាពទូទៅនៃអភិបាលកិច្ច
- និយមន័យ
- គោលបំណង នៃអភិបាលកិច្ច
- តួអង្គ នៃអភិបាលកិច្ច

២-លក្ខណៈ នៃអភិបាលកិច្ច
- ប្រភេទ នៃអភិបាលកិច្ច
- គោលការណ៍ នៃអភិបាលកិច្ច

៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់

៤-គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសំរាប់មន្ត្រីរាជការ

2

## ១-ទិដ្ឋភាពទូទៅនៃអភិបាលកិច្ច

**១.១ និយមន័យ នៃអភិបាលកិច្ច**

- ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ
- អភិបាលកិច្ច ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស (UNDP 1997)

3

## ១-ទិដ្ឋភាពទូទៅនៃអភិបាលកិច្ច (ត)

**១.២ គោលបំណង នៃអភិបាលកិច្ច**

- គ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់ផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ
- អភិបាលកិច្ចទាមទារនូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តភាព

4

## ១-ទិដ្ឋភាពទូទៅនៃអភិបាលកិច្ច (ត)

**១.៣ តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច**

- រដ្ឋាភិបាល
- ផ្នែកឯកជន
- សង្គមស៊ីវិល

5

## ២-លក្ខណៈ នៃអភិបាលកិច្ច

២.១-ប្រភេទ នៃអភិបាលកិច្ច

- អភិបាលកិច្ចសេដ្ឋកិច្ច
- អភិបាលកិច្ចនយោបាយ
- អភិបាលកិច្ចរដ្ឋបាល
- អភិបាលកិច្ចជាប្រព័ន្ធ

6

## ២-លក្ខណៈ នៃអភិបាលកិច្ច (ត)

២.២-គោលការណ៍ នៃអភិបាលកិច្ចៈ

-គិតពីសេវាសាធារណៈ

-ការចូលរួមរបស់ប្រជាពលរដ្ឋ

-នីតិរដ្ឋ

-តម្លាភាព និការឆ្លើយតប

-ការទទួលខុសត្រូវ និងគណនេយ្យភាព

-ការចាត់ចែងល្អ និប្រសិទ្ធភាពខ្ពស់

-ការព្រមព្រៀងឯកភាពគ្នា និងសមធមិ

7

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់

៣.១-អភិបាលិកច្ចក្នុងក្របខ័ណ្ឌយុទ្ធសាស្រ្តចតុកោណ នៃរាជរដ្ឋាភិបាល យុទ្ធសាស្រ្តចតុកោណ មានអភិបាលកិច្ចល្អជាស្នូល សំដៅកំណែទម្រង់លើវិស័យ៤:

-កំណែទម្រង់រដ្ឋបាលសាធារណៈ

-កំណែទម្រង់ច្បាប់ និងតុលាការ

-ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

-កំណែទម្រង់កងកំលាំងប្រដាប់អាវុធ

8

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

៣.២-អភិបាលកិច្ចក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ក-អំណាចដឹកនាំ គ្រប់គ្រងឃុំ សង្កាត់:

-តាមនយោបាយវិមជ្ឈការ

-ជានីតិបុគ្គល

-ដោយក្រុមប្រឹក្សាកើតពីការបោះឆ្នោតជាសកល

-មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចមូលដ្ឋាន

9

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

ខ-គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន

-គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល

10

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

៣.៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ:

ក-អំពីគោលការណ៍ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ:

-រដ្ឋបាលឯកភាព

-បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ

-តាមនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ

11

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

ក-អំពីគោលការណ៍ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ជាស្នូល នៃអភិបាលកិច្ចល្អ រួមមាន:

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ឆ្លើយតប និងគណនេយ្យភាព

12

## ក-អំពីគោលការណ៍ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (ត)

-លើកកំពស់គុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន

-លើកស្ទួយសមធម៌

-តម្លាភាព និងសុច្ចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

13

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

ខ-គណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក

១-គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

-ជម្រើសអាទិភាព ធានាដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ

-រៀបចំផែនការអភិវឌ្ឍន៍ យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍន៍

-ចាត់ចែងកិច្ចការហិរញ្ញវត្ថុ

14

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

ខ-គណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក (ត)

២-គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល

-អំពីការប្រតិបត្តិច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ

-ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន

-ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អភិបាល

ត្រូវមានគណនេយ្យភាពចំពោះក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា

15

## ៣-អភិបាលកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយ ច្បាប់(ត)

ខ-គណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក (ត)

២-ការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះថ្នាក់លើ

បុគ្គលិកទាំងអស់ ត្រូវមានគណនេយ្យភាព :

-ដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន

-ដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សា

16

## ៤-គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសំរាប់មន្ត្រីរាជការ

១-សេវាគឺជាទំនុកចិត្តរបស់សាធារណជន

២-ការខិតខំអស់ពីសមត្ថភាព

៣-ការរក្សាភាពឥតលំអៀង និងត្រឹមត្រូវ

៤-ការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាន

17

## ៤-គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសំរាប់មន្ត្រីរាជការ(ត)

៥-ការគួរសមចំពោះសាធារណជន

៦-ការមិនប្រព្រឹត្តអំពើពុលករលួយ

៧-ជៀសវាងការខ្វះខ្វាយ និងការចាត់ចែងមិនត្រឹមត្រូវ

18

# សូមអរគុណ

19

# ការដោះស្រាយទំនាស់ដោយសន្តិវិធី

# ៥. ការដោះស្រាយទំនាស់ដោយសន្តិវិធី

## ៥.១. គោលបំណង

- យល់ដឹងពីទំនាស់ មូលហេតុ និងផលប៉ះពាល់របស់វា
- ប្រើប្រាស់ដោយមានប្រសិទ្ធភាពនូវឧបករណ៍មួយចំនួនសម្រាប់វិភាគទំនាស់ របៀបគ្រប់គ្រង និងទប់ស្កាត់ទំនាស់
- យល់ដឹងអំពីទ្រឹស្តីផ្សេងៗនៃការធ្វើអន្តរាគមន៍ទំនាស់ដោយសន្តិវិធី
- យល់ដឹងអំពីវិធីដោះស្រាយទំនាស់ដោយសន្តិវិធី ។

## ៥.២. តើអ្វីទៅដែលហៅថាទំនាស់

- ទំនាស់ គឺជាការមិនចុះសំរុងគ្នារវាងមនុស្សពីរនាក់ ឬច្រើននាក់ទៅលើគោលបំណងដែលចង់សម្រេច ឬក៏វិធីសាស្ត្រដើម្បីសម្រេចគោលបំណងនោះ ។
- ការមិនចុះសំរុងនេះ អាចជាការពិត ឬក៏មកពីការយល់ឃើញខុសគ្នារបស់មនុស្ស
- ទំនាស់អាចជាទំនាស់បង្កប់ (ទំនាស់មានហើយ ប៉ុន្តែមិនបញ្ចេញឱ្យដឹង)
- ទំនាស់អាចជាទំនាស់ចំហ (បញ្ចេញជាសកម្មភាពឬពាក្យសំដី) ដែលធ្វើឱ្យយើងមើលឃើញដោយស្រួល ។

## ៥.៣. កម្រិតនៃទំនាស់

ទំនាស់ជាទូទៅត្រូវបានចែកចេញជា :

- **ទំនាស់បុគ្គល (ខ្លួនឯង)** : ខ្លួនយើងដែលជាបុគ្គលម្នាក់ ជាញឹកញាប់តែងតែមានទំនាស់ជាមួយនឹងខ្លួនឯងអំពីតម្លៃនៃជម្រើស ការប្តេជ្ញាចិត្ត អារម្មណ៍ ទំនាក់ទំនង . . . ។ល ។
- **ទំនាស់អន្តរបុគ្គល** : ការខ្វែងមតិរវាងបុគ្គលនៅកម្រិតផ្ទាល់ខ្លួន
- **ទំនាស់អន្តរតួនាទី** : រវាងបុគ្គលពីរនាក់នៅលើមូលដ្ឋាននៃការងារ និងតួនាទីរបស់ពួកគេ

  ឧទាហរណ៍ : រវាងបុរស ឬស្ត្រី នៅគេហដ្ឋានដោយសារការប្រែប្រួលលំនាំការងារ រវាងអ្នកគ្រប់គ្រង ឬកម្មករសហជីពប្រជែងគ្នា . . . ។ល ។
- **ទំនាស់អន្តរក្រុម** : ការខ្វែងមតិរវាងក្រុមផ្សេងៗ ដូចជាអំពីគោលនយោបាយ ឬយុទ្ធសាស្ត្រដែលត្រូវចាត់ទុកថាត្រឹមត្រូវអំពីច្បាប់ អំពីតម្លៃផ្សេងៗ ។
- **ទំនាស់អន្តរសហគមន៍** : រវាងក្រុមធំពីរដែលជាប់ទាក់ទិនគ្នាដោយសារទឹកដី សាសនា ប្រវត្តិសាស្ត្រ ឬទស្សនវិជ្ជា ។ ឧទាហរណ៍ ជ្វីហ្វ អារ៉ាប់ នាយទុន កម្មករ . . .។ល ។
- **ទំនាស់អន្តរជាតិ** : រវាងប្រទេសមួយ និងប្រទេសមួយ ។

## ៥.៤. រូបមន្តបួនជ្រុងនៃទំនាស់

| | | គោលដៅ | |
|---|---|---|---|
| | | ចុះសំរុង | មិនចុះសំរុង |
| អាកប្បកិរិយា | ចុះសំរុង | គ្មានទំនាស់ |  ទំនាស់បង្កប់ |
| | មិនចុះសំរុង |  ទំនាស់ខាងក្រៅ ឬទំនាស់ផ្ទៃរាប |  ទំនាស់ចំហ |

### ៥.៤.១. គ្មានទំនាស់

គ្មានទំនាស់ជាលក្ខណៈមួយដែលគួរឱ្យចូលចិត្តបំផុត។ ប៉ុន្តែក្រុម ឬសង្គមមួយដែលមានសន្តិភាព និងចង់ឱ្យសន្តិភាពយូរអង្វែងត្រូវចេះផ្គុំចូលគ្នានូវទំនាស់រវាងអាកប្បកិរិយា និងគោលដៅ ហើយដោះស្រាយដោយការច្នៃប្រឌិតខ្ពស់។

### ៥.៤.២. ទំនាស់បង្កប់

ទំនាស់បង្កប់ មានន័យថា អាកប្បកិរិយាចុះសំរុងគ្នា ឬចំណែកគោលដៅវិញមិនចុះសំរុងគ្នាទេ ដែលធ្វើឱ្យមានទំនាស់កប់នៅខាងក្នុង។ ទំនាស់នេះបើមិនយកចិត្តទុកដាក់ទេ វានឹងបង្កឱ្យទៅជាទំនាស់ចំហបានយ៉ាងឆាប់រហ័ស។

### ៥.៤.៣. ទំនាស់ចំហ

ទំនាស់ចំហគឺមានទាំងឫសគល់កប់ជ្រៅនៅខាងក្នុង និងអាចមើលឃើញផ្នែកខាងក្រៅផងដែរ។ ទំនាស់នេះតម្រូវឱ្យមានសកម្មភាពដោះស្រាយទាំងឫសគល់ និងឥទ្ធិពលខាងក្រៅ។

### ៥.៤.៤. ទំនាស់ផ្ទៃរាប ឬទំនាស់នៅខាងក្រៅ

ទំនាស់ផ្ទៃរាប ឬទំនាស់នៅខាងក្រៅ ជាទំនាស់ដែលមានភាពសើរៗ ហើយគ្មានចាក់ឫសទេ គឺគ្រាន់តែមានការភាន់ច្រឡំពីគោលដៅ ហើយដែលអាចដោះស្រាយបានដោយគ្រាន់តែពង្រឹងនូវទំនាក់ទំនងរវាងពួកគេឱ្យបានកាន់តែល្អ។

## ៥.៥. ផលវិជ្ជមាន និងអវិជ្ជមាននៃទំនាស់

### ៥.៥.១. ផលវិជ្ជមាន

- យកចិត្តទុកដាក់ផ្ទាល់ទៅនឹងអយុត្តិធម៌សង្គមដែលតម្រូវឱ្យមានការដោះស្រាយ
- ធ្វើឱ្យមានភាពប្រសើរឡើងនូវការផ្លាស់ប្តូរប្រព័ន្ធដែលជាតម្រូវការចាំបាច់ នៅក្នុងអង្គការសង្គម
- អាចនាំឆ្ពោះទៅរកការបង្កើតនូវដំណោះស្រាយបញ្ហា ។

### ៥.៥.២. ផលអវិជ្ជមាន

- អាចនាំឆ្ពោះទៅរកការបំផ្លិចបំផ្លាញនូវអាកប្បកិរិយាល្អ
- អាចបាត់បង់នូវធនធាន និងពេលវេលាដែលចំណាយសម្រាប់បង្កើតសកម្មភាពផ្សេងៗ
- ធ្វើឱ្យមានអារម្មណ៍ឈឺចាប់ដល់ភាគីទាំងឡាយ ។

## ៥.៦. ដើមហេតុនៃទំនាស់

- ភាពផ្សេងៗគ្នានៃចរិតរបស់មនុស្សដែលមានជាប់មកជាមួយរូបយើងតាំងពីកំណើត ។ ឧទាហរណ៍ ចរិតអាត្មានិយម ឆេវឆាវ ដណ្តើមវាគទី និងចរិតកំរោលរបស់មនុស្ស ។
- ទំនាស់កើតឡើងពីឫសគល់ធំបីនៃសកម្មភាព គឺ លោភៈ ទោសៈ និងមោហៈ
- ចរិតរបស់សង្គមមនុស្ស និងទំនោរចិត្តជាលក្ខណៈធម្មជាតិរបស់មនុស្សដែលតែងតែផ្សាភ្ជាប់ទៅនឹងជាតិរដ្ឋ ក្រុមជាតិនានា ក្រុមបុរសឬស្ត្រី ។ ឧទាហរណ៍ មនុស្សយល់ថាក្រុមខ្លួនប្រសើរលើសគេ ។
- រចនាសម្ព័ន្ធសង្គមផ្សេងៗ ដូចជាសង្គមដែលគ្មានការស្មើភាពគ្នារវាងក្រុមទាំងឡាយ និងសង្គមដែលមិនដោះស្រាយតម្រូវការផ្សេងៗ ។ ឧទាហរណ៍ លក្ខណៈមិនស្មើភាពគ្នារវាងបុរស និងស្ត្រី ។
- សេចក្តីត្រូវការនានាជាមូលដ្ឋានរបស់មនុស្សមិនត្រូវបានដោះស្រាយ ។
- ចំណាប់អារម្មណ៍ខុស និងការប្រាស្រ័យទាក់ទងមិនត្រឹមត្រូវ ។ ឧទាហរណ៍ ការយល់ច្រឡំ ចំណាប់អារម្មណ៍មិនត្រឹមត្រូវដោយសារបុរេវិនិច្ឆ័យ ផ្គត់គំនិត ឬទំលាប់ផ្សេងៗ ។
- របួសផ្លូវចិត្តពីអតីតកាល ។ ឧទាហរណ៍ ទំនាស់តពូជពីជីដូនជីតា ។

## ៥.៧. ឧបករណ៍សម្រាប់វិភាគដោះស្រាយជម្លោះ ឬទំនាស់

យើងប្រើប្រាស់ឧបករណ៍សម្រាប់វិភាគទំនាស់ ដើម្បី :

- យល់ដឹងអំពីប្រវត្តិនៃទំនាស់
- យល់ដឹងអំពីក្រុមដែលពាក់ព័ន្ធ
- យល់ដឹងអំពីទស្សនៈការយល់ឃើញរបស់ក្រុមនីមួយៗ
- កំណត់អំពីកត្តាទាំងឡាយ និងមូលហេតុ ក៏ដូចជាទម្ររបស់ទំនាស់

## ៥.៧.១. ដំណាក់កាលនៃទំនាស់

ដើម្បីបង្ហាញអំពីព្រឹត្តិការណ៍សំខាន់ ឬការប៉ះទង្គិចក្នុងទំនាស់ :

- **មុនពេលទំនាស់** : នេះជារយៈពេលមួយ កាលណាមានគោលដៅទាំងឡាយមិនចុះសំរុងគ្នារវាងភាគីពីរ ឬច្រើនដែលអាចនាំទៅរកជម្លោះចំហបាន ។ ជម្លោះគឺត្រូវបានលាក់បាំងពីទស្សនៈទូទៅ ទោះភាគីមួយ ឬច្រើនហាក់បីដូចជាត្រូវបានយល់ដឹងពីសក្តានុពលនៃការប្រឈមមុខក៏ដោយ ។ ប្រហែលជាមានភាពតានតឹងក្នុងទំនាក់ទំនង ប៉ុន្តែនៅមានចំណង់មួយ ដើម្បីជៀសវាងការជួបជាមួយគ្នានៅក្នុងដំណាក់កាលនេះ ។
- **ការប្រឈមមុខ** : ឥឡូវជម្លោះកាន់តែបើកចំហខ្លាំងឡើង ។ ប្រសិនបើភាគីម្ខាងៗមានអារម្មណ៍ថាគឺជាបញ្ហា នោះគេអាចលូកដៃក្នុងការវែកញែកបង្ហាញ ឬក៏មានឥរិយាបថប្រឈមមុខផ្សេងៗ ។ ម្តងម្កាលអាចមានការវាយតប់គ្នា ឬហិង្សាកម្រិតទាបកើតឡើងរវាងភាគីទាំងសងខាង ។ ភាគីទាំងឡាយអាចប្រមូលធនធានរបស់គេ ហើយប្រហែលរិះរកសម្ព័ន្ធមិត្តដោយរំពឹងថា នឹងមានការប្រឈមមុខព្រមទាំងអំពើហិង្សាកើតឡើង ។ ទំនាក់ទំនងរវាងភាគីទាំងសងខាង បានក្លាយទៅជាតានតឹងដែលនាំទៅរកការបែកខ្ញែកដល់អ្នកគាំទ្រទាំងសងខាង ។
- **មហន្តរាយ ឬវិបត្តិ** : ជម្លោះឈានដល់ចំណុចកំពូលនៅពេលដែលមានភាពតានតឹង ហើយឬអំពើហិង្សាមានទំហំធំ ។ ក្នុងទំនាស់ទំហំធំនេះជារយៈពេលនៃសង្គ្រាម នៅពេលដែលប្រជាជនទាំងសងខាងត្រូវបានសម្លាប់ ។ ទំនាក់ទំនងជាធម្មតារវាងភាគីទាំងសងខាងត្រូវបានបញ្ឈប់ ។ សេចក្តីថ្លែងការសាធារណៈមាននិន្នាការឆ្ពោះទៅរកការចោទប្រកាន់ដែលប្រឆាំងគ្នាទាំងសងខាង ។
- **លទ្ធផលថយចុះពីមហន្តរាយ** : មធ្យោបាយមួយ ឬមធ្យោបាយផ្សេងៗទៀតនៃការថយចុះពីមហន្តរាយ នឹងនាំទៅរកលទ្ធផលមួយ ។ ភាគីម្ខាងអាចឈ្នះភាគីម្ខាងទៀត ឬប្រហែលគេនឹងអាចស្នើឱ្យបញ្ឈប់ភ្លើងសង្គ្រាម ( ប្រសិនបើជាសភាពការណ៍សង្គ្រាម) ។ ភាគីម្ខាងអាចចុះចាញ់ ឬផ្តល់ជំនឹចិត្តទៅតាមការស្នើរបស់ភាគីម្ខាងទៀត ។ ភាគីទាំងឡាយអាចព្រមព្រៀងគ្នាដើម្បីធ្វើការចរចា ទោះបីជាមាន ឬគ្មានជំនួយពីអ្នកសម្រុះសម្រួលក៏ដោយ ។ អាជ្ញាធរ ឬភាគីទីបីដែលមានអំណាចជាងគេអាចបង្ខំឱ្យឈប់ប្រយុទ្ធគ្នា ។ នៅក្នុងករណីខ្លះ ដំណាក់កាលនេះ កម្រិតនៃភាពតានតឹង ការប្រឈមមុខនិងហិង្សាបានថយចុះបន្តិចជាមួយស្ថានភាពដែលអាចសម្រុះសម្រួលបាន ។
- **ក្រោយជម្លោះ** : ទីបញ្ចប់ស្ថានភាពត្រូវបាននាំឆ្ពោះទៅរកការថយចុះនៃភាពតានតឹង គឺត្រូវបានដោះស្រាយក្នុងផ្លូវមួយដែលនាំទៅរកការបញ្ចប់នូវការប្រឈមមុខនៃអំពើហិង្សា ព្រមទាំងមានទំនាក់ទំនងជាធម្មតាឡើងវិញរវាងភាគីទាំងឡាយ ។ ម្យ៉ាងទៀត បើសិនជាបញ្ហាទាំងឡាយកើតមានឡើងពីគោលដៅមិនចុះសំរុងគ្នា មិនត្រូវបានដោះស្រាយដោយសមស្របនោះទេ ដំណាក់កាលនេះទីបញ្ចប់នឹងនាំវិលត្រឡប់ទៅរកស្ថានភាពមុនពេលមានជម្លោះមួយទៀត ។

## ដំណាក់កាលនៃជម្លោះ

### ករណីទំនាស់ដីធ្លី នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៨-២០០៦

| មុនពេលមានជម្លោះ | ការប្រឈមមុខ | មហន្តរាយ | លទ្ធផលថយចុះពីមហន្តរាយ | ក្រោយពេលជម្លោះ |
|---|---|---|---|---|
| • មេភូមិដាក់ពាក្យស្នើសុំឱ្យកាន់កាប់ដីពីស្រុក<br>• ខ្វែងគំនិតពីប្រជាពលរដ្ឋ ។ | • ស្មូរិយោដីស្រុកបានអនុញ្ញាតឱ្យមេភូមិកាន់កាប់ដី<br>• មានពាក្យបណ្ដឹងពីប្រជាពលរដ្ឋនិងមេភូមិ<br>• តុលាការសំរេចឱ្យមេភូមិឈ្នះ ។ | • ការអនុវត្តសាលដីការដោយហិង្សា<br>• ប្រជាពលរដ្ឋស្លាប់ចំនួន៦នាក់ និងរបួស៥នាក់<br>• ផ្ទះសម្បែងប្រជាពលរដ្ឋត្រូវឈូសកំទេចចោល ។ | • មេភូមិរត់ចោលស្រុក<br>• រដ្ឋាភិបាលបានរៀបចំឱ្យមានការស៊ើបអង្កេតរកជនដៃដល់<br>• ប្រជាពលរដ្ឋរៀបចំស៊ូមតិ ។ | • មានការដោះស្រាយតាមរយៈការសម្រុះសម្រួលរវាងមេភូមិនិងប្រជាពលរដ្ឋ<br>• អនុញ្ញាតឱ្យប្រជាជនរស់នៅលើដីនោះ<br>• បន្តរកជនដៃដល់ ។ |

## ៥.៧.២. ផែនទីទំនាស់

ផែនទីទំនាស់ជាឧបករណ៍មួយដែលប្រើ សម្រាប់មើលឱ្យកាន់តែច្បាស់នូវទំនាក់ទំនងរវាងភាគីទាំងឡាយពីនាក់ដែលចូលពាក់ព័ន្ធនឹងទំនាស់ដោយផ្ទាល់ ឬដោយប្រយោលដើម្បីកំណត់រកច្រកចូលក្នុងការធ្វើអន្តរាគមន៍។

**ការគូរផែនទីទំនាស់**




**សម្គាល់ :**

- ទំនាក់ទំនងអចិន្ត្រៃយ៍
- ទំនាក់ទំនងសម្ព័ន្ធភាព
- ទំនាក់ទំនងមួងម្កាល
- ប្រអប់បង្ហាញបញ្ហា
- បង្ហាញឥទ្ធិពលលើភាគីម្ខាងទៀង
- ទំនាក់ទំនងមិនចុះសំរុង
- ទំនាក់ទំងត្រូវកាត់ផ្តាច់
- ភាគីខាងក្រៅដែលមានឥទ្ធិពលលើភាគី ប៉ុន្តែមិនចូលរួមក្នុងជម្លោះដោយផ្ទាល់ទេ

ភាគីខាងក្រៅ

## ៥.៧.៣. ត្រីកោណ ប.ឧ.ច

ត្រីកោណប.ឧ.ចជាឧបករណ៍សម្រាប់វិភាគនូវកត្តាទាំងឡាយដែលពាក់ព័ន្ធនឹងបរិបទចិត្ត និងឥរិយាបថរបស់ភាគីនីមួយៗ ដើម្បីកំណត់នូវកត្តាទាំងបីរបស់ភាគីនីមួយៗ ឥទ្ធិពលរបស់កត្តាទាំងបីទៅលើគ្នាទៅវិញទៅមក ដើម្បីរកឱ្យឃើញនូវតម្រូវការ ការភ័យខ្លាចរបស់ភាគីនីមួយៗ និងរកនូវចំណុចចាប់ផ្តើម ដើម្បីធ្វើអន្តរាគមន៍។

ឥរិយាបថ ឬការប្រព្រឹត្ត (ឧ)



ចិត្ត ឬគំនិត (ច) បរិបទ (ប)

- បរិបទ : ជារឿងពិតនៃបញ្ហា ឬជាហេតុការណ៍ ឬជាស្ថានភាពនៅជុំវិញទំនាស់ មើលលើស្ថានភាព ឬហេតុការណ៍នៃប្រវត្តិសាស្ត្រ នយោបាយ រចនាសម្ព័ន្ធសេដ្ឋកិច្ច។
- ឥរិយាបថ : ជាអាកប្បកិរិយា ឬការប្រព្រឹត្តរបស់ភាគីទំនាស់ មើលទៅលើសកម្មភាព របៀបធ្វើសកម្មភាពរបស់ភាគី។
- ចិត្ត : ជាគំនិត ឬការគិតរបស់ភាគី មើលទៅលើចិត្ត អ្វីៗដែលកើតឡើងក្នុងខ្លួនរបស់ភាគី ដូចជាអារម្មណ៍ មិនជឿ សង្ស័យ ឬការភ័យខ្លាច ...។

## ៥.៧.៤. ដើមឈើទំនាស់

ដើមឈើទំនាស់ ជាឧបករណ៍វិភាគតាមគំនូសតាងដោយប្រើប្រាស់រូបភាពដើមឈើ ដែលបង្ហាញនូវការរៀបជាលំដាប់លំដោយនៃមូលហេតុ បញ្ហាស្នូល និងឥទ្ធិពលរបស់ទំនាស់ណាមួយដែលត្រូវយកមកវិភាគ ដើម្បីពិចារណាទៅលើមូលហេតុ និងផលប៉ះពាល់នៃទំនាស់ ជាជំនួយដល់ក្រុមក្នុងការធ្វើដំណើរឆ្ពោះទៅរកការឯកភាពលើបញ្ហាចំបង និងក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅលើដំណោះស្រាយជាអាទិភាពចំពោះទំនាស់ និងដើម្បីបង្ហាញនូវការភ្ជាប់គ្នាទៅវិញទៅមករវាងមូលហេតុ និងផលប៉ះពាល់ ព្រមទាំងបុគ្គល ក្រុម ឬអង្គភាពដែលពាក់ព័ន្ធ។

# ការវិភាគករណីរំលោភផ្លូវភេទលើស្ត្រី និងកុមារ



## ៥.៨. ទ្រឹស្តីអន្តរាគមន៍ទំនាស់

នៅក្នុងទ្រឹស្តីអន្តរាគមន៍ទំនាស់ គេប្រើប្រាស់វិធីសាស្ត្រប្រាំយ៉ាងទៅតាមទិដ្ឋភាពជាក់ស្តែងនៃទំនាស់ :

- **ការទប់ស្កាត់ទំនាស់ :** សំដៅទប់ស្កាត់ការកើតឡើងនៃទំនាស់ហិង្សា
- **ការព្រមព្រៀងជាបណ្តោះអាសន្នលើទំនាស់ :** ជាការព្រមព្រៀងនៅលើទំនាស់ សំដៅបញ្ចប់នូវអាកប្បកិរិយាហិង្សា តាមការឈានទៅដល់ការសម្រេចកិច្ចព្រមព្រៀងសន្តិភាពមួយ ។
- **ការគ្រប់គ្រងទំនាស់ :** សំដៅការកាត់បន្ថយ និងជៀសវាងអំពើហិង្សាទៅអនាគត តាមការលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាននូវឥរិយាបថរបស់គូភាគីជាប់ពាក់ព័ន្ធ ។
- **ការដោះស្រាយទំនាស់ :** ដោះស្រាយពីដើមហេតុនៃទំនាស់ និងព្យាយាមកសាងទំនាក់ទំនងថ្មី និងជាប់លាប់រវាងក្រុមនានាដែលមានទំនាស់ជាមួយគ្នា ។
- **ការបំប្លែងទំនាស់ :** ជាដំណើរការដោះស្រាយទំនាស់ដល់ប្រភពធំទូលាយខាងសង្គមកិច្ច និងនយោបាយនៃទំនាស់ និងព្យាយាមបំប្លែងថាមពលអវិជ្ជមាននៃទំនាស់ឱ្យទៅជាការផ្លាស់ប្តូរជាវិជ្ជមានខាងសង្គមកិច្ច និងនយោបាយ ។

## ៥.៩. ចរន្តនៃការដោះស្រាយទំនាស់ដោយសន្តិវិធី

នៅពេលដែលទំនាស់កើតឡើង គេជ្រើសរើសវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីដោះស្រាយទំនាស់ដែលវិធីសាស្ត្រខ្លះមានផលប្រយោជន៍ និងសន្តិភាពជាងវិធីសាស្ត្រមួយផ្សេងទៀត ។ ក្នុងចរន្តនៃការដោះស្រាយទំនាស់ដោយសន្តិវិធីក្រៅតុលាការជាទូទៅ គេប្រើប្រាស់ការចរចា ការសម្រុះសម្រួល និងអាជ្ញាកណ្តាល ។

### ៥.៩.១. ការចរចា

ក). និយមន័យ

ការចរចាជាដំណើរការដែលភាគីទាំងឡាយ ឬតំណាងរបស់ពួកគេប្រើការបញ្ចុះបញ្ចូល និងការសម្រួលគ្នាដើម្បីដោះស្រាយវិវាទរវាងពួកគេផ្ទាល់ដោយគ្មានភាគីទី៣ ។

ខ). ដំណើការនៃការចរចា

**ដំណាក់កាលទី១ : ការរៀបចំ**

- វិភាគជម្លោះដោយប្រើផែនទីទំនាស់
- ស្រាវជ្រាវ ប្រមូលព័ត៌មានដែលចាំបាច់
- កំណត់តម្រូវការ និងផលប្រយោជន៍របស់ខ្លួនផ្ទាល់ និងភាគីម្ខាងទៀត
- គិតពិចារណានូវជម្រើសរបស់ខ្លួនដែលចង់បានសម្រាប់ជាលទ្ធផលនៃការចរចា ក៏ដូចជាជម្រើសល្អបំផុតសម្រាប់កិច្ចព្រមព្រៀងនៃការចរចា

- ធ្វើទំនាក់ទំនងជាមួយភាគីម្ខាងទៀតដើម្បីព្រមព្រៀងលើទីកន្លែង ព្រមទាំងដំណើរការដោយរាប់បញ្ចូល :
  - បទបញ្ជាផ្ទៃក្នុង
  - បញ្ហាដែលត្រូវយកមកពិភាក្សា
  - ចំនួនមនុស្សដែលត្រូវចូលរួម រួមទាំងជំនួយការរបស់ភាគីម្ខាងៗ ។

## ដំណាក់កាលទី២ : សកម្មភាពក្នុងការចរចា

- នៅពេលទៅដល់កន្លែងត្រូវជម្រាបសួរគ្នាទៅវិញទៅមកដើម្បីកសាងការចុះសំរុងគ្នា និងជំនឿជាក់
- ការចែករំលែកជាមួយគ្នានូវគំនិតផ្សេងៗ អំពីស្ថានភាពរបស់អ្នក
- បង្កើតនូវជម្រើសផ្សេងៗសម្រាប់ដោះស្រាយនូវបញ្ហានោះ
- វាយតម្លៃ និងឱ្យអាទិភាពលើជម្រើសនេះ យល់ព្រមនូវតម្រូវការ និងផលប្រយោជន៍របស់ភាគីទាំងសងខាង
- ជ្រើសរើសនូវជម្រើសល្អបំផុត និងបញ្ចូលគ្នានូវជម្រើសដែលបញ្ចូលគ្នាបាន ។

## ដំណាក់កាលទី៣ : បិទ

- បង្កើតកិច្ចព្រមព្រៀង (តើជម្រើស ឬការបញ្ចូលគ្នាណាមួយដែលអាចឱ្យយើងទាំងអស់គ្នាគាំទ្របាន?)
- បង្កើតផែនសកម្មភាព (តើភាគីម្ខាងៗត្រូវធ្វើយ៉ាងដូចម្តេចដើម្បីអនុវត្តកិច្ចព្រមព្រៀង?)
- ដាក់ផែនការសម្រាប់រំឭកឡើងវិញនូវកិច្ចព្រមព្រៀងនោះ ។

គ). គោលការណ៍ទាំងឡាយនៃការចរចា

- **ចូរស្តាប់ដោយយកចិត្តទុកដាក់ចំពោះភាគីមួយទៀត** : ទោះបីជាអ្នកមិនយល់ស្របនឹងអ្វីដែលគេនិយាយក៏ដោយ អ្នកអាចទទួលបានដំណឹងសំខាន់ៗអំពីផលប្រយោជន៍ និងស្ថានភាពរបស់ភាគីម្ខាងទៀត ហើយអ្នកអាចស្ថិតក្នុងស្ថានភាពប្រសើរមួយ ដើម្បីអាចរកវិធីដោះស្រាយទំនាស់បាន ។
- **ចូរចៀសវាងការទិតៀនផ្ទាល់ខ្លួន** : ផ្តោតទៅលើរឿងរ៉ាវ និងបញ្ហាទាំងឡាយ មិនមែនផ្តោតទៅលើបុគ្គលទេ ។ ជារឿយៗ មនុស្សមានកំហឹង និងស្អប់ស្អាញនៅពេលទំនាស់កើតមានឡើង ។ ចូរព្យាយាមជជែកអំពីរឿងរ៉ាវ និងចៀសវាងការប៉ុនប៉ងទិតៀនដោយផ្ទាល់មាត់ទៅលើគូភាគី ។
- **ស្វែងរកដំណោះស្រាយដោយផ្អែកទៅលើផលប្រយោជន៍ទៅវិញទៅមក** : ព្យាយាមរកឱ្យឃើញនូវផលប្រយោជន៍ និងគោលបំណងទាំងឡាយរបស់ភាគីម្ខាងទៀត និងបង្កើតដំណោះស្រាយទាំងឡាយដែលឱ្យគូភាគីទាំងអស់ទទួលបាននូវអ្វីដែលគេត្រូវការ ដើម្បីបំពេញប្រយោជន៍ និងសម្រេចបំណងរបស់គេ ។

- ប្រសិនបើអ្នកសម្រេចនូវដំណោះស្រាយមួយ សូមឱ្យច្បាស់ថាវាមានភាពច្បាស់លាស់ និងងាយយល់ ៖ សូមឱ្យច្បាស់ថាភាគីទាំងអស់ច្បាស់លាស់ និងយល់គ្នាទៅវិញទៅមកលើពាក្យពេចន៍នៃកិច្ចព្រមព្រៀង។ ជាញឹកញាប់វាអាចមានប្រយោជន៍ក្នុងការចុះកិច្ចសន្យា ឬយ៉ាងហោចណាស់សរសេរយ៉ាងលំអិតអំពីការដោះស្រាយ និងមានការចុះហត្ថលេខាពីភាគីនីមួយៗ។

### ៥.៩.២. ការសម្រុះសម្រួល

ក). និយមន័យនៃការសម្រុះសម្រួល

ការសម្រុះសម្រួល គឺជាដំណើរការធ្វើអន្តរាគមន៍របស់ភាគីទី៣ រវាងភាគីជម្លោះពីរ ឬច្រើនដើម្បីធ្វើឱ្យសម្រេចនូវអ្វីដែលជាតម្រូវការរបស់ពួកគេ។

ខ). តួនាទីរបស់អ្នកសម្រុះសម្រួល

- ធ្វើការងារប្រាស្រ័យទាក់ទង
- ធ្វើឱ្យរីកលូតលាស់ទៅមុខ
- មនុស្សដែលគេទុកចិត្ត និងអាចប្រាប់រឿងរ៉ាវបាន
- ផ្សះផ្សា
- គាំទ្រការបង្កើតគំនិតថ្មីៗ
- ស្វែងរកចំណុចជាជំនួយដើម្បីសម្រួលក្នុងការសម្រុះសម្រួល
- សម្រុះសម្រួលដើម្បីសម្រេចនូវកិច្ចព្រមព្រៀង

គ). ដំណាក់កាលនៃការសម្រុះសម្រមួល

- **ការបើក**

  ការចាប់ផ្តើម និងការព្រមព្រៀង ៖ ធ្វើឱ្យមានភាពកក់ក្តៅដោយធ្វើការអធិប្បាយ ការរៀបចំពិភាក្សារកវិធីឈ្នះឈ្នះ

- **ការបង្កើត**

  ធ្វើការពិនិត្យត្រួសៗលើអ្វីដែលជារឿងហេតុ លើកទឹកចិត្តភាគីម្នាក់ៗបង្ហាញពីទស្សនះរបស់ខ្លួន ចំពោះបញ្ហាទំនាស់ផ្សេងៗ និងអារម្មណ៍របស់ពួកគេ។

- **ធ្វើការលំអិត**

  ធ្វើការលំអិតទៅលើ ៖ តើអ្វីខ្លះដែលទាក់ទិនក្នុងជម្លោះ? ធ្វើឱ្យលំអិតលើសពីនេះទៀតលើផែនទី និងដាក់ខ្សែទំនាក់ទំនងឱ្យបានច្បាស់លាស់ ញែករវាងការព្រួយបារម្ភ និងសេចក្តីត្រូវការ។ ធ្វើការបំភ្លឺឡើងវិញនូវអ្វីដែលយល់ខុស ហើយរករឿងរ៉ាវដែលជាចំនុចពិតដោយប្រើប្រាស់ការឆ្លុះបញ្ចាំងផ្សេងៗ ។

- **វិកិលទៅមុខ**

  ពិនិត្យមើលឡើងវិញ ថាតើគេបានមកដល់ណាហើយ? រកមើលថាតើគេបានព្រមព្រៀងលើចំណុចអ្វីខ្លះមកទល់ពេលនេះ? ជំរុញឱ្យគេបានវិកិលទៅមុខទៀត ។ បើចាំបាច់ត្រូវធ្វើការជួបដោយឡែក ។
- **ការចរចា**

  ត្រូវយកចិត្តទុកដាក់លើសកម្មភាពនាពេលអនាគត ។ តើគេចង់បានឱ្យទៅជារបៀបណា? តើគេចង់ធ្វើរបៀបណា? បង្កើតជម្រើសដោយប្រើការចរចារបៀបជូញដូរ ដើម្បីកសាងឱ្យបានឈ្នះទាំងអស់គ្នា ។
- **ការបិទ**

  ការធ្វើឱ្យបានគ្រប់បរិបូរ : ធ្វើកិច្ចព្រមព្រៀង ធ្វើគម្រោងសម្រាប់អនាគត ព្រមទាំងការកំណត់នូវពេលវេលាសម្រាប់ពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង និងធ្វើសេចក្តីថ្លែងការបញ្ចប់ ។

## ឃ). វិធីសាស្ត្រសម្រុះសម្រួល

- បង្កើតឱ្យមានបទប្បញ្ញត្តិសាមញ្ញ : ស្តាប់ដោយប្រុងប្រយ័ត្ន និយាយពីគំនិតរបស់ខ្លួនឱ្យបានច្បាស់លាស់ ធ្វើការវាយប្រហារចំពោះបញ្ហា មិនមែនតម្រង់ចំពោះបុគ្គលទេ រកមើលចម្លើយណាដែលសម្រេចបាននូវតម្រូវការរបស់ពួកគេ
- ឱ្យនិយមន័យពីតួនាទីសម្រុះសម្រួលរបស់អ្នក គឺដើម្បីជួយឱ្យអ្នកទាំងសងខាងឈ្នះទាំងអស់គ្នា
- ចាប់យកកិច្ចព្រមព្រៀងទាំងសងខាងចំពោះចេតនារម្មណ៍របស់គេក្នុងការជួសជុលបញ្ហារបស់ពួកគេ
- អនុញ្ញាតឱ្យភាគីនិយាយពីបញ្ហារបស់គេ ហើយបញ្ជាក់ភាគីម្ខាងទៀត ដើម្បីបញ្ជាក់ថាគេបានយល់ច្បាស់
- ដឹកនាំការសន្ទនាឆ្ពោះទៅរកការដោះស្រាយបញ្ហារួមគ្នា និងជៀសវាងការវាយប្រហារបុគ្គល
- ជំរុញឱ្យពួកគេខិតខំរកមើលនូវចម្លើយណា ដែលធ្វើឱ្យពួកគេបាននូវសេចក្តីត្រូវការរបស់ពួកគេ
- ធ្វើការផ្លាស់ប្តូរពាក្យសំដីមិនសមរម្យ ។